**នៅចំពោះមុខអង្គបុរេជំនុំជម្រះ**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/០៧-០៩-២០០៩-អវតក/កសចស(អបជ៦១) |
| **ដាក់ទៅ** | : | អង្គបុរេជំនុំជម្រះ |
| **ថ្ងៃដាក់** | : | ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 25-Mar-2020, 15:50
CMS/CFO: Sann Rada

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** **សម្ងាត់**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គបុរេជំនុំជម្រះ:** សម្ងាត់/Confidential

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្ដោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

**ការឆ្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ទៅនឹងចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្ដឹងឧទ្ធរណ៍របស់គាត់ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ប្រឆាំង យឹម ទិត្យ (D381)**

---

**អ្នកដាក់ឯកសារ:**
លោកស្រី Brenda J HOLLIS
សហព្រះរាជអាជ្ញាអន្តរជាតិ

**ចម្លងជូន:**
លោកស្រី ជា លាង
សហព្រះរាជអាជ្ញាជាតិ

**អ្នកទទួលឯកសារ:**

**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គឹមសាន
ចៅក្រម Olivier BEAUVALLET
ចៅក្រម ន័យ ធុល
ចៅក្រម Kang Jim BAIK
ចៅក្រម ហួត វុទ្ធី

**មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់នៃសំណុំរឿង០០៤**

**សហមេធាវីការពារក្ដី យឹម ទិត្យ**
លោក សូ មូស្សេទ្ធី
លោកស្រី Suzana TOMANOVIĆ

## I. ចម្លើយតប

1. សហព្រះរាជអាជ្ញាអន្តរជាតិ ("ស.ព.អ") សូមធ្វើការឆ្លើយតបទៅនឹងចម្លើយតបរបស់ យឹម ទិត្យ[1] ទៅនឹងបណ្តឹងឧទ្ធរណ៍[2] របស់ ស.ព.អ ប្រឆាំងនឹងដីកាដំណោះស្រាយ ("ដីកាសម្រេចលើកលែងចោទប្រកាន់") របស់សហចៅក្រមស៊ើបអង្កេតជាតិ[3]។ យឹម ទិត្យ តវ៉ាទាំងខុសថា ការចេញដីកាដំណោះស្រាយពីរដែលខុសច្បាប់ គឺធ្វើឲ្យដីកាទាំងពីរគ្មានសុពលភាព អាស្រ័យហេតុនេះ បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ លែងយកជាការណ៍បាន និងគួរត្រូវបានទាត់ចោលយ៉ាងសង្ខេប[4]។ អាស្រ័យដូចមូលហេតុចែងខាងក្រោម អំណះអំណាងរបស់ យឹម ទិត្យ (i) យល់ច្រឡំអំពីសេចក្តីពិចារណារបស់អង្គបុរេជំនុំជម្រះ ("អ.ប.ជ") លើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ ("សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២")[5], (ii) យល់ច្រឡំចំពោះវិធាន ៦៧(២)[6] នៃវិធានផ្ទៃ និង (iii) ខកខានមិនបានបង្ហាញពីថាតើ ការចេញដីកាដំណោះស្រាយផ្ទុយគ្នាពីរ រំលោភសិទ្ធិក្នុងការទទួលបានការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌នោះទេ។ អាស្រ័យហេតុនេះ ឧបាស្រ័យដែល យឹម ទិត្យ បានស្នើសុំឲ្យ

---

[1] ឯកសារ **D381/26** ចម្លើយតបរបស់ យឹម ទិត្យ ទៅនឹងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិប្រឆាំងនឹងដីកាដំណោះស្រាយរបស់សហចៅក្រមស៊ើបអង្កេតជាតិ, ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ("ចម្លើយតបរបស់ យឹម ទិត្យ")។

[2] ឯកសារ **D381/19** បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាអន្តរជាតិ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ (D381), ចុះថ្ងៃទី៤ ខែធ្នូ ឆ្នាំ២០១៩ ("បណ្តឹងឧទ្ធរណ៍របស់ ស.ព.អ")។

[3] ឯកសារ **D381** ដីកាសម្រេចលើកលែងចោទប្រកាន់ យឹម ទិត្យ, ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩, កថាខណ្ឌ ៦៨៦។

[4] ឯកសារ **D381/26** ចម្លើយតបរបស់ យឹម ទិត្យ, កថាខណ្ឌ ១, ៧, ៣១, EN 01637754។ យឹម ទិត្យ មិនឆ្លើយតបទៅនឹងទឡ្ហីករណ៍នៃបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ទេ ទាក់ទងនឹងដីកាសម្រេចលើកលែងចោទប្រកាន់។ *សូមមើល ឧ.* កថាខណ្ឌ ១, ៧, ២៧, ៣០។

[5] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណាលើបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ, ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៩ ("សេចក្តីពិចារណាលើដីកាដំណោះស្រាយរបស់ អ.ប.ជ")។

[6] អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា, វិធានផ្ទៃក្នុង (វិសោធនកម្មលើកទី ៩) ដែលបានកែប្រែនៅថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៥ ("វិធាន" ឬ "វិធានផ្ទៃក្នុង")។

បដិសេធ[7]លើដីកាដំណោះស្រាយ ("ដីកាបញ្ជូនរឿងទៅជំនុំជម្រះ")[8] របស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិនោះ គឺគ្មានសេចក្តីទេ។

## II. សេចក្តីសន្និដ្ឋាន

### ក. សេចក្តីពិចារណាក្នុងសំណុំរឿង ០០៤/២ មិនបង្ហាញថា ដីកាដំណោះស្រាយ *ទាំងពីរ* គ្មានសុពលភាពទេ

2. ជារឿងងាយៗ ការពិតដែលចៅក្រម អ.ប.ជ ទាំងប្រាំរូប បានពិចារណាលើអង្គសេចក្តីនៃដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ នៅក្រោយការកំណត់ថា *ការចេញ* ដីកាផ្ទុយគ្នាពីរ គឺខុសច្បាប់ បានយកឈ្នះលើអំណះអំណាងរបស់ យឹម ទិត្យ និងធ្វើឲ្យចម្លើយតបរបស់គាត់គ្មានអង្គសេចក្តី។ សេចក្តីពិចារណាបញ្ជាក់ចំពោះការពិតថា កំហុសផ្នែកនីតិវិធីនៃ*ការចេញ* ដីកាដំណោះស្រាយផ្ទុយគ្នាពីរ ក៏មិនធ្វើឲ្យដីកាដំណោះស្រាយ គ្មានសុពលភាពនោះដែរ។ ផ្ទុយមកវិញ ដូចចៅក្រមបានអនុវត្តនៅក្នុងសេចក្តីពិចារណាអឺចឹង គឺថា ដីកាដំណោះស្រាយនីមួយៗត្រូវតែមានការពិនិត្យឡើងវិញ ដើម្បីកំណត់ថាតើមានកំហុសសំខាន់ណាមួយដែលនឹងអនុញ្ញាតឲ្យមានការច្រានចោលដីកាដំណោះស្រាយមួយ ឬទាំងពីរ ដែរឬអត់។ ប្រសិនបើ អ.ប.ជ បានរកឃើញថា ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ គ្មានសុពលភាពមែននោះ ម្ល៉េះចៅក្រមទាំងប្រាំរូបមិន (i) បានស្នើឲ្យមាន "អំណាចពិនិត្យឡើងវិញជាពិសេស"[9] និង "ប្រើប្រាស់អំណាចពិនិត្យឡើងវិញដ៏ទូលំទូលាយទាំងនោះ *ដើម្បីស្តារឡើងវិញចំពោះនីត្យានុកូល និងឧបាស្រ័យ ដែលជាការមួលបង្កាច់នីតិវិធី* បណ្តាលមកពីសកម្មភាពខុសច្បាប់របស់សហចៅក្រមស៊ើបអង្កេតនៅក្នុងករណីនេះ"[10], (ii) បានប្រកាសថា "រកមិនបានសំឡេងគាំទ្រយ៉ាងតិចបួនសំឡេង

---

[7] ឯកសារ **D382** ដីកាដំណោះស្រាយ, ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៩, EN 01620059-71។

[8] ឯកសារ **D381/26** ចម្លើយតបរបស់ យឹម ទិត្យ, កថាខណ្ឌ ១, ៣៣, EN 01637754-55។

[9] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណាលើដីកាដំណោះស្រាយរបស់ អ.ប.ជ, កថាខណ្ឌ ១២៤។

[10] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណាលើដីកាដំណោះស្រាយរបស់ អ.ប.ជ, កំណត់សំគាល់ជើងទំព័រ ៥៩ (សង្កត់ន័យដើម)។ *សូមមើលផងដែរ* កថាខណ្ឌ ៤៧ ["អង្គបុរេជំនុំជម្រះកត់សំគាល់ថា អំណាចពិនិត្យឡើងវិញ

ចំពោះសេចក្តីសម្រេចដោយផ្អែកលើ *សំអាងហេតុរួមលើអង្គសេចក្តី*[11], (iii) បានបញ្ជាក់យ៉ាងច្បាស់ថា "ផលប៉ះពាល់" នៃការរកឃើញរបស់ពួកគាត់អំពី*ការចេញ* ដីកាដំណោះស្រាយបែកជាពីរ ត្រូវបានលើកឡើងនៅក្នុងមតិដាច់ដោយឡែករបស់ពួកគាត់[12] ឬ (iv) បានពិចារណាលើអង្គសេចក្តីនៃដីកាដំណោះស្រាយ[13] នោះឡើយ។ តាមពិត គ្មានចៅក្រមណាម្នាក់ ទាំងចៅក្រមជាតិ ឬចៅក្រមអន្តរជាតិ បានរកឃើញថា ដីកាដំណោះស្រាយ *ទាំងពីរ* គ្មានសុពលភាពនោះទេ[14]។

3. អាស្រ័យហេតុនេះ និងផ្ទុយពីការអះអាងរបស់ យឹម ទិត្យ ដែលថា "អ.ប.ជ បានសម្រេចតម្កល់យ៉ាងមានប្រសិទ្ធិភាពចំពោះអំណះអំណាងរបស់មេធាវីការពារក្តី"[15]នោះ តាមការពិតស កម្មភាពជាឯកច្ឆន្ទរបស់ អ.ប.ជ ក្នុងសំណុំរឿង ០០៤/២ បង្ហាញយ៉ាងហច្បាស់ថា ដីកាដំណោះស្រាយក្នុងសំណុំរឿង ០០៤/២ មិនត្រូវបានទុកជាមោឃៈទេ ដែលនេះជាមូលដ្ឋានច្បាប់យ៉ាងច្បាស់ក្រឡែតដែលផ្តល់ឲ្យមាន

---

របស់ខ្លួនក្នុងនាមជាអង្គជំនុំជម្រះស៊ើបអង្កេតដំបូងទី២ អាចរួមមាន (i) អំណាចរបស់អង្គជំនុំជម្រះស៊ើបអង្កេតដើម្បីបោសសម្អាតលើភាពមិនប្រក្រតីណាមួយនៅក្នុងនីតិវិធីដែលអង្គជំនុំជម្រះនេះត្រូវបានប្តឹង មុននឹងបញ្ជូនសំណុំរឿងនេះទៅជំនុំជម្រះ"]។

[11] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណាលើដីកាដំណោះស្រាយរបស់ អ.ប.ជ, EN 01634239 (ផ្នែកសម្រេចសេចក្តី) (សង្កត់ន័យដើម)។

[12] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណាលើដីកាដំណោះស្រាយរបស់ អ.ប.ជ, កថាខណ្ឌ ៨៩, ១២៤។

[13] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណាលើដីកាដំណោះស្រាយរបស់ អ.ប.ជ, មតិយោបល់របស់ចៅក្រម ប្រាក់ គឹមសាន, ចៅក្រម ន័យ ថុល និងចៅក្រម ហួត វុទ្ធី ("យោបល់របស់ចៅក្រមជាតិ"), កថាខណ្ឌ ២០៤-២៩៤ និងយោបល់របស់ចៅក្រម Baik និង Beauvallet ("យោបល់របស់ចៅក្រមអន្តរជាតិ"), កថាខណ្ឌ ៣០៣-៦៨៤។

[14] ចៅក្រមជាតិបានថ្លែងថា ផលប៉ះពាល់គឺថា ដីកាដំណោះស្រាយ (ដីកាលើកលែងចោទប្រកាន់) [...] ត្រូវបានតម្កល់"។ ចៅក្រមអន្តរជាតិបានថ្លែងថា ផលប៉ះពាល់គឺថា ដីកាដំណោះស្រាយ (ដីកាបញ្ជូនរឿងទៅជំនុំជម្រះ) [...] យកជាបានការ"។ *សូមមើល* សំណុំរឿង ០០៤/២-ឯកសារ **D359/24** & ឯកសារ **D360/33** សេចក្តីពិចារណាលើដីកាដំណោះស្រាយរបស់ អ.ប.ជ, EN 01634276 (យោបល់របស់ចៅក្រមជាតិ) និងកថាខណ្ឌ ៣២៦ (យោបល់របស់ចៅក្រមអន្តរជាតិ)។

[15] ឯកសារ **D381/26** ចម្លើយតបរបស់ យឹម ទិត្យ, កថាខណ្ឌ ១១។

ចំណាត់ការទៅលើបណ្តឹងឧទ្ធរណ៍ ដូច្នេះ បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយរបស់ ស.ព.អ មិនមែនលែងយកជាការបាននោះឡើយ[16]។

## ខ. វិធាន ៦៧(២) នៃវិធានផ្ទៃក្នុង មិនអនុវត្តចំពោះវិបាកនៃការចេញ ដីកាដំណោះស្រាយពីរផ្ទុយគ្នាទេ

4. យឹម ទិត្យ ធ្វើមិនដឹងមិនឮចំពោះអត្ថន័យធម្មតា និងគោលបំណងនៃវិធាន ៦៧(២) នៃវិធានផ្ទៃក្នុង ដោយអះអាងទាំងខុសថា វិធាននេះគ្រប់គ្រងលើវិបាកនៃការចេញ ដីកាដំណោះស្រាយពីរផ្ទុយគ្នា[17]។ ពាក្យពេចន៍វិធាន ៦៧(២) នៃវិធានផ្ទៃក្នុងនេះ គឺច្បាស់លាស់៖ វាអនុវត្តផ្តាច់មុខចំពោះតែដីកាបញ្ជូនរឿងទៅជំនុំជម្រះ និងចែងថា ដីកាបញ្ជូនរឿងទៅជំនុំជម្រះនេះ ត្រូវបានចាត់ទុកជាមោឃៈ*ជាបឋមវៀរលែងតែ* ខ្លឹមសារនៃដីកានេះមិនមានបញ្ជាក់អំពី "អត្តសញ្ញាណនៃជនជាប់ចោទ ការបង្ហាញអំពីអង្គហេតុ និងការកំណត់ប្រភេទបទល្មើស [...] ក្នុងនោះមានទាំងបទប្បញ្ញត្តិនៃបទឧក្រិដ្ឋដែលពាក់ព័ន្ធ និងប្រភេទនៃការទទួលខុសត្រូវព្រហ្មទណ្ឌ"[18]។ ប្រសិនបើអ្នកតាក់តែងវិធានមានបំណងចង់ដាក់បញ្ចូលលក្ខណវិនិច្ឆ័យផ្សេងទៀត ម្ល៉េះពួកគេបានដាក់វាបញ្ចូលហើយ។ ហេតុដូច្នេះ យើងគ្មានចន្លោះប្រហោងនៅក្នុងវិធាន ៦៧(២) ដូច ការអះអាងខុសរបស់ យឹម ទិត្យ ទេ ហើយជម្រើសចុងក្រោយរបស់គាត់ចំពោះបទប្បញ្ញត្តិអំពីមោឃភាពលើកិច្ចស៊ើបសួរដែលមិនពាក់ព័ន្ធនោះ តាមសទិសភាព គឺគ្មានមូលដ្ឋានឡើយ[19]។ យឹម ទិត្យ មិនត្រឹមតែមិនអើពើចំពោះពាក្យពេចន៍ធម្មតានៃវិធាន ៦៧(២) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះទេ គាត់ក៏ធ្វើមិនដឹងមិនឮចំពោះវិធាន ៤៨ ផងដែរ ដែលពាក់ព័ន្ធនឹងមោឃភាពនៃវិការៈនីតិវិធី និងលក្ខខណ្ឌតម្រូវក្នុងការបង្ហាញអំពីការប៉ះពាល់លើសិទ្ធិរបស់ជនណាម្នាក់។ គាត់ខកខានមិនបានកំណត់អត្តសញ្ញាណអំពីច្បាប់របស់ អ.វ.ត.ក ណាមួយ ដែលគាំទ្រដល់ការអះអាងរបស់គាត់ដែលថា

---

[16] *ឯកសារផ្ទុយ* **D381/26** ចម្លើយតបរបស់ យឹម ទិត្យ, កថាខណ្ឌ ១, ៧, ២៧, ៣០-៣១។

[17] ឯកសារ **D381/26** ចម្លើយតបរបស់ យឹម ទិត្យ, កថាខណ្ឌ ១៣-១៦, ២៦។

[18] កត់សំគាល់ទាក់ទងនឹងចំណុចនេះថា វិធាន ៦៧(២) ប្រើពាក្យ "ដីកាបញ្ជូនរឿងទៅជំនុំជម្រះ" ដែលជាវាក្យខណ្ឌមួយនៃដីកាដំណោះស្រាយ គឺជាលិខិតុបករណ៍នៃការចោទប្រកាន់ ខណៈវិធាន ៦៧(៤) ប្រើភាសា "ដីកាដំណោះស្រាយ"។ គេគ្រាន់តែអាចធ្វើការសន្និដ្ឋានបានថា ភាពខុសគ្នានៃការប្រើពាក្យពេចន៍ គឺជាចេតនា មិនមែនជារឿងចៃដន្យឡើយ។

[19] ឯកសារ **D381/26** ចម្លើយតបរបស់ យឹម ទិត្យ, កថាខណ្ឌ ១៤-២៦។

ការចេញដីកាដំណោះស្រាយពីរផ្ទុយគ្នាដែលខុសច្បាប់ នាំឲ្យដីកាទាំងពីរគ្មានសុពលភាពនោះទេ ហើយគាត់ខកខានទាំងស្រុងក្នុងការបង្ហាញនូវបុរេនិច្ឆ័យដូចដែលបានតម្រូវ។

### គ. យឹម ទិត្យ ខកខានមិនបានបង្ហាញថាតើ *ការចេញ* ដីកាដំណោះស្រាយពីរខ្វែងគ្នា រំលោភលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់គាត់ យ៉ាងដូចម្ដេចនោះទេ

5. យឹម ទិត្យ ខកខានមិនបានបង្ហាញថាតើ *ការចេញ* ដីកាដំណោះស្រាយពីរខ្វែងគ្នា រំលោភលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់គាត់ យ៉ាងដូចម្ដេចនោះទេ[20]។ ហើយគាត់ក៏មិនបានបង្ហាញពីរបៀបចាត់ការទៅតាមការទទួលស្គាល់របស់ អ.ប.ជ ស្ដីពីគោលជំហរស្វ័យប្រវត្តិជាមូលដ្ឋាន និងជាកត្តាកំណត់ ក្នុងក្របខណ្ឌច្បាប់ អ.វ.ត.ក នោះដែរ *គឺមានន័យថា* ដីកាបញ្ជូនរឿងទៅជំនុំជម្រះ *ត្រូវ* ប្ដឹងឲ្យអង្គជំនុំជម្រះសាលាដំបូង ("អ.ជ.ស.ដ") ចាត់ការ លើកលែងតែវាត្រូវបានបដិសេធដោយសេចក្ដីសម្រេចដែលមានសំឡេងភាគច្រើនលើសលុប ដែលវាអាចរំលោភលើសិទ្ធិក្នុងការទទួលបាននូវការកាត់សេចក្ដីដោយត្រឹមត្រូវរបស់គាត់[21]។ អង្គជំនុំជម្រះតុលាការកំពូល ("អ.ជ.ត.ក") បានសម្រេចថា "ពុំមែនកំហុសនៃកិច្ចដំណើរការនីតិវិធីទាំងអស់សុទ្ធតែនាំទៅរកការកែប្រែសាលក្រមនោះឡើយ លើកលែងតែកំហុសនោះបណ្ដាលឲ្យ "មានលទ្ធផលមិនយុត្តិធម៌ទាំងស្រុង នៅក្នុងកិច្ចដំណើរការនីតិវិធីរបស់តុលាការ""[22]។ ការចេញចេញដីកាដំណោះស្រាយពីរ និងការបញ្ជូនដីកាបញ្ជូនរឿងទៅជំនុំជម្រះដើម្បីកាត់សេចក្ដី មិនរំលោភលើគោលការណ៍ស្ដីពី *វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់ជន*

---

[20] ឯកសារ **D381/26** ចម្លើយតបរបស់ យឹម ទិត្យ កថាខណ្ឌ ៣៣, KH 01639364។

[21] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ១០៦-១០៧, ១១១-១១២, ១១៦-១១៧ និងការលើកឡើងនៅក្នុងនោះ។ *សូមមើលផងដែរ* វិធាន ៧៩(១), ៧៧(១៣)(ខ)។ សំណុំរឿង ០០១-ឯកសារ **F28** សាលដីកា ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០១២ កថាខណ្ឌ ៦៥។ ឯកសារ **D381/25** ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិទៅនឹងបណ្ដឹងឧទ្ធរណ៍របស់ យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ នៅក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ("ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ") កថាខណ្ឌ ៣១-៣៣, ៥០, ៤៩, ៣៥។

[22] សំណុំរឿង ០០២-ឯកសារ **F36** សាលដីកា ចុះថ្ងៃទី២៣ ខែវិច្ឆិកា ឆ្នាំ២០១៦ កថាខណ្ឌ ១០០។

*ជាប់ចោទ* នោះទេ[23]។ បន្ថែមលើនេះ អ.ប.ជ បានសង្កត់ធ្ងន់ថា ដំណាក់កាលមុនការជំនុំជម្រះក្ដី "មិនពាក់ព័ន្ធនឹងការកំណត់ថា មានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាព" នោះទេ ហើយថា "សច្ចធារណ៍នៃនិរទោសត្រូវបានការពារគ្រប់គ្រាន់ ដោយហេតុថា អនុលោមតាមវិធាន ៩៨(៤) *ការសម្រេចផ្ដន្ទាទោស* នៅក្នុងដំណាក់កាលជំនុំជម្រះក្ដី ទាមទារឲ្យមានសំឡេងគាំទ្រយ៉ាងហោចណាស់ពីចៅក្រមបួនរូបនិងនៅពេលរកសម្លេងភាគច្រើនតាមតម្រូវការមិនបានទេ "មានន័យថា ជនជាប់ចោទត្រូវរួចផុតពីបទចោទ""[24]។ ជាងនេះទៀត យឹម ទិត្យ ខកខានមិនបានបំពេញគោលការណ៍ដែលថា វាមិនមែនគ្រាន់តែជាសិទ្ធិរបស់គាត់នោះទេដែលអង្គជំនុំជម្រះនេះត្រូវតែយកចិត្តទុកដាក់នោះ។ វិធាន ២ នៃវិធានផ្ទៃក្នុង បានណែនាំឲ្យអង្គជំនុំជម្រះត្រូវ "ផ្ដោតការយកចិត្តទុកដាក់ពិសេសទៅលើគោលការណ៍ជាមូលដ្ឋានដែលមានចែងក្នុងវិធាន ២១ នៃវិធានផ្ទៃក្នុងនេះ"[25] ដែលធានានូវផលប្រយោជន៍ មិនគ្រាន់តែចំពោះ យឹម ទិត្យ ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងចំពោះជនរងគ្រោះផងដែរ ហើយផ្ដល់អាណត្តិដល់កិច្ចដំណើរការនីតិវិធីត្រឹមត្រូវមួយ ដែលរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីនានា[26]។ តុល្យភាពនេះគាំទ្រដល់ការផ្សះផ្សាជាតិតាមរយៈការធានាដល់ជនរងគ្រោះនៃឧក្រិដ្ឋកម្ម ថាពួកគេមានសម្លេងមួយប្រកបដោយអត្ថន័យ[27] ក្នុង

---

[23] *សូមមើល* ឯកសារ **D381/25** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ៤១-៤៥។ *ផ្ទុយពី* ឯកសារ **D381/26** ចម្លើយតបរបស់ យឹម ទិត្យ កថាខណ្ឌ ៣៣។

[24] សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ១៦៣ (សង្កត់ន័យដើម)។ *សូមមើលផងដែរ* សំណុំរឿង ០០២-ឯកសារ **E176/2/1/4** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខរបស់ នួន ជា ប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងលើសំណើសុំឲ្យចាត់ការជាបន្ទាន់ តាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០១២ កថាខណ្ឌ ៥២។

[25] *សូមមើលផងដែរ* ឯកសារ **D381/25** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ៥៦។

[26] *សូមមើលផងដែរ* សំណុំរឿង ០០៤/២-ឯកសារ **D359/24** & **D360/33** សេចក្ដីពិចារណារបស់ អ.ប.ជ លើដីកាដំណោះស្រាយ កថាខណ្ឌ ៥១។ សំណុំរឿង **D381/25** ចម្លើយតបរបស់ ស.ព.អ ទៅនឹងបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ កថាខណ្ឌ ៥៥។

[27] សំណុំរឿង ០០២-ឯកសារ **D411/3/6** សាលដីកាលើគ្រប់បណ្ដឹងឧទ្ធរណ៍ទាំងអស់ប្រឆាំងនឹងដីកាសម្រេចនានារបស់ សហចៅក្រមស៊ើបអង្កេត លើភាពអាចទទួលយកបាននៃពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចុះថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០១១ កថាខណ្ឌ ៦៤-

ខណៈដែលសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះដោយត្រឹមត្រូវយុត្តិធម៌របស់ជនជាប់ចោទ ត្រូវបានការពារ។

## ឃ. ឧបាស្រ័យដែលស្នើឡើងដោយ យឹម ទិត្យ គឺមិនសមរម្យទេ

6. ចំពោះមូលហេតុដូចបានថ្លែងខាងលើ[28] សំណើរបស់ យឹម ទិត្យ ដែលស្នើឲ្យបដិសេធដីកាបញ្ជូនរឿងទៅជំនុំជម្រះដោយសារការបាត់បង់សិទ្ធិទាំងស្រុង និងឲ្យបដិសេធចោលទាំងស្រុងនូវបណ្ដឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់នោះ គឺមិនស៊ីចង្វាក់គ្នាជាមួយនឹងសេចក្ដីពិចារណាលើសំណុំរឿង០០៤/២ ទេ ដូច្នេះសំណើនេះត្រូវតែបដិសេធចោល[29]។

7. បន្ថែមលើនេះ សំណើរបស់ យឹម ទិត្យ សុំឲ្យបដិសេធសំណុំរឿង០០៤ នេះ គឺធ្វើមិនដឹងមិនឮពីលក្ខខណ្ឌតម្រូវកម្រិតខ្ពស់បំផុតសម្រាប់ការបញ្ចប់ ឬការផ្អាកកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ដូច្នេះហើយសំណើនេះត្រូវតែបានបដិសេធចោល[30]។ អ.ជ.ត.ក និង អ.ជ.ស.ដ បានសម្រេចថា គេគ្មានសិទ្ធិអំណាចណាមួយបង្គាប់ឲ្យបញ្ចប់ ក្រៅពីហេតុផលយ៉ាងច្បាស់លាស់តាមមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា នោះទេ គឺ៖ មរណភាពនៃជនល្មើស ការផុតអាជ្ញាយុកាល ការលើកលែងទោសជាទូទៅ និរាករណ៍នៃច្បាប់ និង *អាជ្ញាអស់ជំនុំ*[31]។

---

៦៥។ កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្ដីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្ម ដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០០៣ បុព្វកថា។

[28] *សូមមើល ខាងលើ* កថាខណ្ឌ ២-៣។

[29] *ផ្ទុយពី* ឯកសារ **D381/26** ចម្លើយតបរបស់ យឹម ទិត្យ កថាខណ្ឌ ១, ៧, ៣១ EN 01637754-55។

[30] ឯកសារ **D381/26** ចម្លើយតបរបស់ យឹម ទិត្យ កថាខណ្ឌ ១, ៣៣ EN 01637754។

[31] សំណុំរឿង ០០២-ឯកសារ **E138/1/10/1/5/7** សេចក្ដីសម្រេចលើបណ្ដឹងសាទុក្ខភ្លាមៗប្រឆាំងនឹងសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូងដែលបង្គាប់ឲ្យដោះលែងជនជាប់ចោទ អៀង ធីរិទ្ធ ដោយឥតលក្ខខណ្ឌ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២ កថាខណ្ឌ ៣៨។ សំណុំរឿង ០០២-ឯកសារ **E116** សេចក្ដីសម្រេចលើសំណើរបស់ជនជាប់ចោទ នួន ជា ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃកិច្ចស៊ើបសួរ (ឯកសារ E51/3, E82, E88 និង E92) ចុះថ្ងៃទី៩ ខែកញ្ញា ឆ្នាំ២០១១ កថាខណ្ឌ ១៦-១៧។ ច្រកចូលដ៏ខ្ពស់នេះគឺបានឆ្លុះបញ្ចាំងផងដែរនូវមាត្រា ៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌបារាំង និងច្បាប់យុត្តិសាស្ត្រអន្តរជាតិ កាលណាវិធានការបែបដូច្នេះត្រូវបានអនុញ្ញាតកាល

8. បន្ថែមលើនេះ សេចក្តីសន្និដ្ឋានរបស់ យឹម ទិត្យ ដែលថា "អ.ប.ជ [...] ត្រូវបំពេញកិច្ចជាក់លាក់ស្រប តាមការសម្រេចជាឯកច្ឆន្ទរបស់ខ្លួន" នៅក្នុងសំណុំរឿង ០០៤/២[32] បានធ្វើឲ្យខូចខាតទាំងស្រុងនូវសំណើសុំរបស់គាត់ ព្រោះថា សកម្មភាពជាឯកច្ឆ័ន្ទរបស់ អ.ប.ជ នៅក្នុងករណីនោះ បានធ្វើឲ្យខូចខាតដល់ការអះអាងរបស់ យឹម ទិត្យ ពាក់ព័ន្ធនឹងសុពលភាពផ្លូវច្បាប់នៃដីកាដំណោះស្រាយនៅក្នុងសំណុំរឿង ០០៤។

## III. ខ្ចចាស្រ័យដែលស្នើឡើង

9. យោងតាមបណ្តឹងឧទ្ធរណ៍របស់ ស.ព.អ ប្រឆាំងនឹងដីកាសម្រេចលើកលែងចោទប្រកាន់ ស.ព.អ ស្នើសុំឲ្យ អង្គជំនុំជម្រះសាលាដំបូង៖

i. បដិសេធចោលនូវបណ្តឹងឧទ្ធរណ៍របស់ យឹម ទិត្យ ស្តីពីការចេញដីកាដំណោះស្រាយពីរខ្វែងគ្នា នៅក្នុងសំណុំរឿង០០៤[33]។

ii. បដិសេធចោលនូវដីកាសម្រេចលើកលែងការចោទប្រកាន់។

iii. តម្កល់ដីកាបញ្ជូនរឿងទៅជំនុំជម្រះ។ និង

iv. បញ្ជូនសំណុំរឿង០០៤ ទៅជំនុំជម្រះ តាមមូលដ្ឋាននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ៕

---

ណាមានការផ្អាកត្រូវបានពិចារណា គឺមានតែដំណោះស្រាយដែលអាចធានាបាននូវភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី *តែប៉ុណ្ណោះ* ឬបើមិនដូច្នោះទេ គឺបដិសេធពុំបានដាច់ខាត នៅក្នុងផលប្រយោជន៍នៃយុត្តិធម៌។ *សូមមើល ខ១.* Karadžić សំណុំរឿង IT-95-5/18-T អង្គជំនុំជម្រះសាលាដំបូង សេចក្តីសម្រេចលើញត្តិស្នើសុំផ្អាកកិច្ចដំណើរការនីតិវិធី ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១០ កថាខណ្ឌ ៩។ *Lubanga Dyilo* សំណុំរឿង ICC-01/04-01/06-772 អង្គជំនុំជម្រះសាលាឧទ្ធរណ៍ សាលដីកាលើបណ្តឹងសាទុក្ខរបស់លោក Thomas Lubanga Dyilo ប្រឆាំងនឹងសាលក្រមលើការជំទាស់របស់មេធាវីការពារក្តីពីយុត្តាធិការរបស់តុលាការ អនុលោមតាមមាត្រា ១៩(២)(ក) នៃច្បាប់លក្ខន្តិកៈថ្ងៃទី៣ ខែតុលា ឆ្នាំ២០០៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៦ កថាខណ្ឌ ៣០។

[32] ឯកសារ **D381/26** ចម្លើយតបរបស់ យឹម ទិត្យ កថាខណ្ឌ ៣៤។

[33] ឯកសារ **D381/18** & **D382/21** បណ្តឹងឧទ្ធរណ៍របស់លោក យឹម ទិត្យ ប្រឆាំងនឹងការចេញដីកាដំណោះស្រាយចំនួនពីរ នៅក្នុងសំណុំរឿង០០៤ ចុះថ្ងៃទី២ ខែធ្នូ ឆ្នាំ២០១៩។

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០២០ | លោកស្រី **Brenda J. HOLLIS** សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |